## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ: ៤៧៥
ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៣
<u>សាលដីកា</u>
លេខ: ១០៧
ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៤

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណ: នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................. ជាចៅក្រម
៥-លោក ................ ជាចៅក្រមរបាយការណ៍

**<u>ក្រឡាបញ្ជី</u>**

-លោក .................

**<u>តំណាងមហាអយ្យការ</u>**

-ឯកឧត្តម ............... ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ៦៣(ឈ) ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៩៨ ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ រវាង:

ដើមចោទឈ្មោះអសរ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦២ឆ្នាំ ជាតិខ្មែរ មុខរបរនាយកសាជីវកម្មធនាគារសិង្ហបូរីចំកាត់ ទីលំនៅសព្វថ្ងៃផ្ទះលេខ៦៨ វិថីសម្តេចប៉ាន សង្កាត់ បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។ តំណាងដោយឈ្មោះ ជម ។

ចុងចម្លើយឈ្មោះ អយរ(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៥៤ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ៣ ផ្លូវលេខ១៤៦ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ អុំ ពូ ម្តាយឈ្មោះភីម អ៊ុត ប្រពន្ធឈ្មោះសសស ។

លោក ផសផ ជាមេធាវីការពារ ។

**<u>កម្មវត្ថុបណ្តឹ:</u>** ប្តឹងទាមទារប្រាក់

បានឃើញបណ្តឹងសាទុក្ខលេខ ៣២៤ ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ២០០៣ របស់ឈ្មោះ អយរប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៣(ឈ) ចុះថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៧៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការ កំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១០-៨-២០០១របស់ឈ្មោះអសរ ប្តឹងទាមទារប្រាក់ពីឈ្មោះ អយរនិងប្រពន្ធឈ្មោះសសស ដោយសំអាងហេតុថា អ្នកទាំងពីរបានខ្ចីប្រាក់ពីធនាគារ របស់ខ្លួនតាមកិច្ចសន្យាចុះថ្ងៃទី២៩-៨-២០០០ ចំនួន ៥០.០០០ដុល្លាអាមេរិក និងតាមកិច្ចសន្យាចុះ ថ្ងៃទី២៨-១០-២០០០ ចំនួន ២០.០០០$US សរុប ៧០.០០០$US ដោយដាក់បញ្ចាំវិឡាលេខ៣ ផ្លូវ១៨៦ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ៦៤២ ចុះថ្ងៃទី២៧-៨-១៩៩២ ។ កិច្ចសន្យាខ្ចីប្រាក់ត្រូវផុតកំណត់នៅថ្ងៃទី ២៨-១២-២០០១ រហូតមក ដល់ថ្ងៃនេះអ្នកទាំងពីរមិនទាន់សង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១០៧(ខ) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១០-៨-២០០១ របស់ដើមចោទនាយកសាជីវកម្ម ធនាគារសិង្ហបូរីចំកាត់ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ការផ្ទេរសិទ្ធិរបស់ដើមចោទ ចុះថ្ងៃទី១០-០៨-២០០១ ឱ្យឈ្មោះ ជិត ម៉ៅ ចូលជាតំណាងរបស់ខ្លួន ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលស្គាល់ការផ្ទេរសិទ្ធិរបស់ចុងចម្លើយឈ្មោះអយរតាមលិខិតចុះថ្ងៃទី ១៨-១០-២០០១ ឱ្យមេធាវីឈ្មោះ លីម ច័ណ្ឌប៊ុនកែវ ចូលជាតំណាង និង ការពារក្តីឱ្យខ្លួន ទុក ជាត្រឹមត្រូវតាមច្បាប់ ។

៤-បង្គាប់ឱ្យឈ្មោះ អយរនិងឈ្មោះសសស ជាប្តីប្រពន្ធសងប្រាក់ដើម ចំនួន $US៧០.០០០ (ប្រាំពីរម៉ឺនដុល្លាអាមេរិក) និងការប្រាក់តាមអត្រា១.៥% ក្នុងមួយខែលើប្រាក់ដើម៥០០០០ដុល្លា គិតពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ រហូតដល់ថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០០១ និង លើប្រាក់ដើម $US២០.០០០ (ពីរម៉ឺនដុល្លាអាមេរិក)គិតពីថ្ងៃទី២៨-១០-២០០០ រហូតដល់ថ្ងៃទី២៨-០២-២០០១ និង ឲ្យសងការប្រាក់តាមអត្រា ៣% ក្នុងមួយខែលើប្រាក់ដើម $US ៧០.០០០ (ប្រាំពីរម៉ឺនដុល្លាអាមេរិក)គិតពីថ្ងៃទី០១-៣-២០០១ រហូតដល់ថ្ងៃសងប្រាក់រួចគ្រប់ចំនួន ឱ្យទៅសាជីវកម្ម ធនាគារសិង្ហបូរីចំកាត់ ។

៥-បើឈ្មោះ អយរនិងឈ្មោះសសស ជាប្តីប្រពន្ធគ្មានលទ្ធភាពសង ត្រូវកត់ត្រា និងរឹបអូសផ្ទះលេខ៣ ផ្លូវលេខ ១៨៦ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលខ ១១៦៤២ថ្ងៃទី ២៧-៨-១៩៩២ ដោយការិយាល័យ សុរិយោដីក្រុងភ្នំពេញ ដែលបានដាក់បញ្ចាំលក់ឡាយឡុងសងបំណុលខាងលើ បើមិនគ្រប់ចំនួន ត្រូវ រឹបអូសទ្រព្យសម្បត្តិដទៃទៀត ដើម្បីលក់ឡាយឡុងសងបង្គ្រាប់ចំនួន ក្នុងករណីរឹងទទឹងត្រូវចាប់ដាក់គុកបង្ខំលើរូបកាយ ដើម្បីទារប្រាក់តាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើ តាមក្រឹត្យលេខ ៥១ក្រ ចុះថ្ងៃទី០២-៥-១៩៩២ ។

៦-បង្គាប់ឱ្យឈ្មោះ អយរនិង ឈ្មោះ សសស ជាប្តីប្រពន្ធបង់ប្រាក់ ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់ អ្នកប្រគល់ដីកាកោះ ៥០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ ទុករួចហើយ ។

កាលបើផុតកំណត់ប្តឹងឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះ អយរនិងប្រពន្ធ សងប្រាក់ ៧.០០០៛ ទៅឱ្យដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ១% លើប្រាក់ដែលត្រូវសងទាំងអស់ ប្រាក់នេះត្រូវ បង់ចូលថវិការដ្ឋ ៨០% និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៧-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទ កំបាំងមុខមេធាវី តំណាងចុងចម្លើយ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤៥(ខ) ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ឈ្មោះ លឹម ច័ន្ទប៊ុនកែវ ជាមេធាវី ការពារឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១០៧(ខ) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសាលក្រម ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៣(ឈ)ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣-១១-២០០១ របស់លោកមេធាវីឈ្មោះ លឹម ច័ន្ទប៊ុនកែវ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១០៧(ខ) ចុះថ្ងៃទី០២-១១-២០០១ របស់ តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលចុងបណ្តឹងឧទ្ធរណ៍បានបង់ជួសដើមបណ្តឹងរួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០រៀល ។ កាលបើផុតបណ្តឹងសាទុក្ខ បង្គាប់ឲ្យ ដើមបណ្តឹងឧទ្ធរណ៍សងប្រាក់ ១៣.០០០៛ នេះ ទៅចុងបណ្តឹងឧទ្ធរណ៍វិញ ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី ១៨-០៤-២០០៣ ចំពោះមុខ តំណាងដើមចោទ កំបាំងមុខចុងចម្លើយ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៤-៤-២០០៣ ចំពោះមុខតំណាងដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣២៤ ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ២០០៣ របស់ឈ្មោះអយរប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៣(ឈ) ចុះថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា សូមកុលាការសម្រេចតាមកិច្ចសន្យា គូភាគីចុះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ផសផ ជាមេធាវីការពារឱ្យលោក អយរនាពេលសវនាការថា : ខ្លួនទើបបានទទួលសិទ្ធិពីលោក អយរថ្មីៗនេះទេ ដូច្នេះ ខ្លួនពុំមាន ឯកសារដើម្បីធ្វើសេចក្តីសន្និដ្ឋានក្នុងរឿងនេះឡើយ ហេតុនេះ សូមតុលាការកំពូលសម្រេចយ៉ាងណា សម្រេចចុះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះដម តំណាងឱ្យ អូវ ស៊ុនរឹង នាពេលសវនាការថាៈ ដូចចៅក្រមអានរបាយការណ៍ គឺត្រឹមត្រូវហើយ ចុងចម្លើយខ្ចីប្រាក់ពីធនាគារត្រូវសងធនាគារវិញ ទាំងដើម ទាំងការ ព្រោះធនាគារក៏បង់ពន្ធជូនរដ្ឋដែរ ។ បើមិនសងទេ សុំឲ្យ តុលាការអនុវត្ត តាមច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយតំណាងដើមចោទ និងចម្លើយមេធាវីចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣២៤ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ របស់លោកអយរធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា លោក អយរនិងអ្នកស្រីសសស បានខ្ចីចងការប្រាក់ពីសាជីវកម្មធនាគារសិង្គបូរីចំកាត់ នូវប្រាក់ដើមចំនួន ៧០.០០០ដុល្លាអាមេរិក (ប្រាំពីរម៉ឺនដុល្លាអាមេរិក)ចំនួនពីរលើក ដោយលើកទី១ ចំនួន ៥០.០០០ដុល្លាអាមេរិក(ប្រាំម៉ឺនដុល្លាអាមេរិក) និងលើកទី២ចំនួន ២០.០០០ ដុល្លាអាមេរិក (ពីរម៉ឺនដុល្លាអាមេរិក) ដែលមានចុះកិច្ចសន្យា នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ និងកិច្ចសន្យាចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០០ ជាមួយធនាគារជាភស្តុតាងស្រាប់ ។ ដូច្នេះ លោកអយរនិងអ្នកស្រីសសស មានកាតព្វកិច្ចអនុវត្តគ្រប់លក្ខខ័ណ្ឌទាំងឡាយ ដែលមានចែងក្នុងកិច្ចសន្យាទាំងនេះ តាមមាត្រា ២២ និង ២៩ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ។

- យល់ឃើញថា មេធាវីចុងចម្លើយ បានដាក់ពាក្យសុំពន្យាពេលសវនាការនេះទៅថ្ងៃក្រោយ ដោយហេតុថា លោកទើបតែទទួលចំណាយក្តីនេះ ពុំទាន់មានឯកសារ ហើយនៅពេល សវនាការនេះ ក៏លោកនៅតែសំណូមពរដូច្នេះដែរ ។ តុលាការកំពូលពុំអាចពន្យាពេលបានទេ ពី ព្រោះ រឿងក្តីនេះ ចុងចម្លើយបានទទួលស្គាល់បំណុលតាមកិច្ចសន្យារួចហើយ ហើយការពន្យាពេល នាំឱ្យគូភាគីមានការខាតបង់កាន់តែច្រើនថែមទៀត ។ ម៉្យាងទៀត ចុងចម្លើយក៏មានមេធាវីម្នាក់ ទៀតដែរ គឺលោកលឹម ច័ន្ទប៊ុនកែវ ប៉ុន្តែលោកលឹមច័ន្ទប៊ុនកែវពុំបានចូលរួមនាសវនាការនេះដែរ។

- យល់ឃើញថា ចុងចម្លើយបានទទួលលិខិតបង្គាប់ឱ្យធ្វើសារណារួចហើយ ប៉ុន្តែលោកពុំ បានធ្វើសារណាជូនតុលាការកំពូលទេ ហើយក៏ពុំបានមកចូលរួមនាសវនាការនេះដែរ មានតែមេធាវី មកចូលរួម ដូច្នេះ តុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៦៣(ឈ) ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ទាំងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីចំពោះមុខដើមចោទ**

**កំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្ដឹងសាទុក្ខលេខ ៣២៤ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០៣ របស់លោក អយរទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៦៣(ឈ) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០៛ ដែលអ្នកស្រីជម បានបង់ទុកនៅតុលាការកំពូលគឺៈ

-ពន្ធចុះបញ្ជីក្ដី នឹងពន្ធហ្នឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជា រង្វាន់ក្រឡាបញ្ជីកាត់ហិបប្រាក់,

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០៛ ហើយតម្រូវឱ្យលោក អយរសងប្រាក់ចំនួន ១៩.០០០៛ នេះទៅឱ្យអ្នកស្រី ជម វិញ ។

បង្គាប់ឱ្យលោកអយរបង់ពន្ធសមាមាត្រចំនួនមួយភាគរយ លើប្រាក់ទាំងអស់ដែលត្រូវ សងទៅដើមចោទ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៤ ។